សាលាដំបូងខេត្តកោះកុង
សំណុំរឿងព្រហ្មទណ្ឌ
លេខ ០១
ចុះថ្ងៃទី ១២-០៣-២០២០
សាលក្រមព្រហ្មទណ្ឌ
លេខ: ៦១ "ក"
ចុះថ្ងៃទី ៣០-០៤-២០២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកោះកុង

បានបើកសវនាការជាសាធារណៈនៅសាលជំនុំជម្រះនៃសាលាដំបូងខេត្តកោះកុង នាថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ២:៣០នាទីល្ងាច ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ប្រធានសាលាដំបូងខេត្តកោះកុង

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

**មេធាវីការពារក្តី**

-លោក[redacted]

-ដើម្បីជំនុំជម្រះលើ សំណុំរឿងព្រហ្មទណ្ឌលេខ: ០១ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ដែលមានជនជាប់ចោទឈ្មោះ [redacted]រ៉ា ភេទស្រី អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តស្វាយរៀង មានទីលំនៅបច្ចុប្បន្ន កំពុងជាប់អនុវត្តទោសនៅពន្ធនាគារខេត្តកោះកុង ឪពុកឈ្មោះ [redacted] អ៊ុច (រ) ម្តាយឈ្មោះ [redacted] រ៉ន (រ) ប្តីឈ្មោះ [redacted] សាម៉ន (រ) មានកូន ០៣នាក់ ទោសពីមុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី៣១-០៧-២០១៧) ។

**កម្មវត្ថុ: សុំស្រុបទោសបញ្ចូលគ្នានៅក្នុងសាលក្រមព្រហ្មទណ្ឌ:**

**១-លេខ: ១០១"ក" ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង។**

**២-លេខ: ១០២"ក" ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង។**

-បានឃើញ: ពាក្យបណ្តឹងសុំស្រុបទោសចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ទណ្ឌិតឈ្មោះ [redacted]រ៉ា ភេទស្រី អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ ។

-បានឃើញ: លិខិតបញ្ជាក់កិរិយាមារយាទលេខ: ២៤៣ ព.គ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ របស់ប្រធានពន្ធនាគារខេត្តកោះកុង ។

-បានឃើញ:សាលក្រមព្រហ្មទណ្ឌលេខ: ១០១"ក" ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន០៣(បី)ឆ្នាំ *ពីបទ:* ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ០២ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៧ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

- បានឃើញ:សាលក្រមព្រហ្មទណ្ឌលេខ: ១០២"ក" ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០៤(បួន)ឆ្នាំ តែទោសនេះត្រូវ/

អនុវត្តដាក់ក្នុងពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរទាំងអស់ *ពីបទៈ* ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ០២ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

**អង្គហេតុមានដូចតទៅ**

-កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ទណ្ឌិតឈ្មោះ [redacted] វ៉ា ភេទស្រី អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ បានដាក់ពាក្យបណ្តឹងសុំស្រូបទោសបញ្ចូលគ្នា នៅក្នុងសាលក្រមព្រហ្មទណ្ឌលេខៈ **១០១"ក"** ចុះថ្ងៃទី **០៤ ខែកក្កដា ឆ្នាំ២០១៨** របស់សាលាដំបូងខេត្តកោះកុង និង សាលក្រមព្រហ្មទណ្ឌលេខៈ **១០២"ក"** **ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨** របស់សាលាដំបូងខេត្តកោះកុង ។ ដោយមូលហេតុៈ ឆ្លងតាមការអប់រំនៅក្នុងពន្ធនាគារខេត្តកោះកុង ខ្លួនបានដឹងពីទោសកំហុសរបស់ខ្លួន ដែលបានប្រព្រឹត្តនាពេលកន្លងមក និងខិតខំកសាងខ្លួនដើម្បីក្លាយជាមនុស្សល្អ ឈប់ប្រព្រឹត្តអំពើល្មើស ឬបង្ករបញ្ហាអ្វីទៀតដល់សង្គម ហើយសន្យាថា វិលទៅរួមរស់ក្នុងសង្គមវិញ ដោយភាពត្រឹមត្រូវ និងគោរពទៅតាមច្បាប់ ។

**នាពេលសវនាការ**

-ទណ្ឌិតឈ្មោះ [redacted] វ៉ា បានឆ្លើយបញ្ជាក់ថាៈ ខ្លួនធ្លាប់ត្រូវបានសាលាដំបូងខេត្តកោះកុង ផ្តន្ទាទោសចំនួន ០២ សាលក្រម តាមសាលក្រមព្រហ្មទណ្ឌលេខៈ **១០១"ក" ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ** **២០១៨** របស់សាលាដំបូងខេត្តកោះកុង និងសាលក្រមព្រហ្មទណ្ឌលេខៈ **១០២"ក" ចុះថ្ងៃទី០៤ ខែ** **កក្កដា ឆ្នាំ២០១៨** របស់សាលាដំបូងខេត្តកោះកុង ។ សាលក្រមព្រហ្មទណ្ឌទាំង ០២ សាលក្រម ខាងលើ ខ្លួនមិនបានប្តឹងឧទ្ធរណ៍ទេ ហើយសព្វថ្ងៃនេះសាលក្រមព្រហ្មទណ្ឌទាំង ០២ សាលក្រម នេះ បានចូលជាស្ថាពរហើយ ។ រយៈពេលដែលខ្លួនអនុវត្តទោសនៅក្នុងពន្ធនាគារខេត្តកោះកុង ខ្លួនបានដឹងពីកំហុស ហើយបានគោរពអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិន័យ បទបញ្ជាផ្ទៃក្នុងនៅក្នុងពន្ធនាគារខេត្តកោះកុង និងយកចិត្តទុកដាក់ក្នុងសកម្មភាពការងារពលកម្ម និងរៀនវិជ្ជាជីវៈ ដោយស្មារតីភ្ញាក់រលឹក ខ្លួននឹងយកចិត្តទុកដាក់បំពេញការងារឲ្យបានល្អ ដើម្បីជាគំរូល្អដល់ទណ្ឌិតដទៃទៀត និងប្តេជ្ញាថាធ្វើជាពលរដ្ឋល្អជាប្រយោជន៍ដល់សង្គមក្រោយពេលអនុវត្តទោសចប់ ។ រហូតមកដល់ពេលនេះខ្លួនបានអនុវត្តទោសបានចំនួន **០២(ពីរ)ឆ្នាំ ០៨(ប្រាំបី)ខែ ០៧ (ប្រាំពីរ)ថ្ងៃ** រួចមកហើយ ហើយខ្លួនមានឯកសារបញ្ជាក់កិរិយាមារយាទ ពីប្រធានពន្ធនាគារខេត្តកោះកុង ។ ខ្លួនសំណូមពរសុំឲ្យតុលាការ មេត្តាស្រូបទោសបញ្ចូលគ្នាឲ្យខ្លួនផង ។ ប្រសិនបើតុលាការ ស្រូបទោសឲ្យខ្លួន ហើយបើខ្លួនបានចេញទៅវិញ ខ្លួនមានគោលដៅទៅធ្វើស្រែនៅស្រុកកំណើត នៅខេត្តកំពង់ចាម ។

**-តំណាងអយ្យការនាពេលសវនាកាបានធ្វើសេចក្តីសន្និដ្ឋានថាៈ** ឆ្លងតាមការសួរដេញដោលនាពេលសវការរួចមកឃើញថាៈ ទណ្ឌិតឈ្មោះ [redacted] វ៉ា ត្រូវបានសាលាដំបូងខេត្តកោះកុងផ្តន្ទាទោសចំនួន **០២សាលក្រម** ស្មើនឹងទោសចំនួន **០៦(ប្រាំមួយ)ឆ្នាំ** តាមសាលាក្រមព្រហ្មទណ្ឌលេខៈ **១០១"ក"** **ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨** របស់សាលាដំបូងខេត្តកោះកុង និងសាលក្រមព្រហ្មទណ្ឌលេខៈ **១០២"ក" ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨** របស់សាលាដំបូងខេត្តកោះកុង ។ ហើយសាលក្រមព្រហ្មទណ្ឌទាំង ០២នេះ បានចូលជាស្ថាពរអស់ហើយ ហើយទណ្ឌិតឈ្មោះ [redacted] វ៉ា បានអនុវត្តទោសនៅក្នុងពន្ធនាគារខេត្តកោះកុង បានចំនួន **០២(ពីរ)ឆ្នាំ ០៨(ប្រាំបី)ខែ ០៧ (ប្រាំពីរ)ថ្ងៃ** រួចហើយដែរ ។ ពាងនាមអយ្យការខ្លួនស្នើរសុំឲ្យតុលាការ ពិចារណា និងសម្រេចតាមច្បាប់ ។



Scanned with CamScanner

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យទណ្ឌិតឈ្មោះ [redacted] រ៉ា បានលើកឡើងថាៈ កូនក្តីរបស់ខ្លួនត្រូវបានសាលាដំបូងខេត្តកោះកុង សម្រេច ផ្តន្ទាទោស មាន ០២សាលក្រមៈ ដោយសាលក្រមទី១ លេខៈ ១០១-ក- ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០៣(បី)ឆ្នាំ *ពីបទៈ* ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងសាលក្រមទី២ លេខៈ ១០២-ក- ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០៤ (បួន) ឆ្នាំ តែទោសនេះត្រូវអនុវត្តដាក់ក្នុងពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរទាំងអស់ *ពីបទៈ* ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ហើយសាលក្រមទាំង ០២នេះ បានចូលជាស្ថាពរអស់ហើយ រយៈពេលដែលកូនក្តីខ្លួនអនុវត្តទោស នៅក្នុងពន្ធនាគារខេត្តកោះកុង កូនក្តីខ្លួនបានដឹងពីកំហុស ហើយបានគោរពវិន័យបទបញ្ជាផ្ទៃក្នុង នៅក្នុងពន្ធនាគារ ហើយកូនក្តីខ្លួនបានយកចិត្តទុកដាក់ ក្នុងសកម្មភាពការងារពលកម្ម និងរៀនវិជ្ជាជីវៈ ដោយស្មារតីភ្ញាក់រលឹក ។ រហូតមកដល់ពេលនេះកូនក្តីខ្លួនបានអនុវត្តទោសបានចំនួន ០២(ពីរ)ឆ្នាំ ០៨(ប្រាំបី)ខែ ០៧ (ប្រាំពីរ)ថ្ងៃ រួចហើយ ជាពិសេសនៅក្នុងពេលនេះកុណក្តីខ្លួនមានជំងឺទឹកនោមផ្អែម ប្រចាំកាយទៀតផង ។ ខ្លួនសំណូមពរសុំឲ្យតុលាការមេត្រាជួយស្រូបទោសបញ្ចូលគ្នាឲ្យកូនក្តីខ្លួនតាមសាលក្រមព្រហ្មទណ្ឌលេខៈ ១០១-ក- ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ និងសាលក្រមព្រហ្មទណ្ឌលេខៈ ១០២-ក- ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ ។

-ទណ្ឌិតឈ្មោះ [redacted] រ៉ា បាននិយាយសម្តី និងសំណូមពរចុងក្រោយបង្អស់ សុំឲ្យតុលាការមេត្តាស្រូបទោសបញ្ចូលគ្នាឲ្យខ្លួនផង ។

-ក្រោយពីស្តាប់ចម្លើយទណ្ឌិត

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យទណ្ឌិត

-ក្រោយពីបានស្តាប់សម្តី និងសំណូមពរចុងក្រោយរបស់ទណ្ឌិត

## សាលាដំបូងខេត្តកោះកុង

## ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយៈ

## យល់ឃើញថាៈ

- តាមពាក្យបណ្តឹងសុំស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ របស់ទណ្ឌិតឈ្មោះ [redacted] រ៉ា ធ្វើឡើងនៅក្នុងកំណត់ច្បាប់ តុលាការអាចទទួលយកមកជំនុំជម្រះបានយោងតាមមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

- តាមចម្លើយទណ្ឌិតឈ្មោះ [redacted] រ៉ា បានឆ្លើយថាៈ ខ្លួនប្តឹងសុំស្រូបទោសបញ្ចូលគ្នាតាមសាលក្រមព្រហ្មទណ្ឌលេខៈ ១០១-ក- ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង និងសាលក្រមព្រហ្មទណ្ឌលេខៈ ១០២-ក- ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង ។

-យោងសាលក្រមព្រហ្មទណ្ឌលេខៈ ១០១-ក- ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន០៣(បី)ឆ្នាំ *ពីបទៈ* ជួញដូរដោយខុស



Scanned with CamScanner

ច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ០២ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៧ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-យោងសាលក្រមព្រហ្មទណ្ឌលេខៈ **១០២-ក-** ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០៤(បួន)ឆ្នាំ តែទោសនេះត្រូវអនុវត្តដាក់ក្នុងពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរទាំងអស់ *ពីបទៈ* ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ០២ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

-ទណ្ឌិតឈ្មោះ [redacted] រ៉ា ត្រូវបានសាលាដំបូងខេត្តកោះកុង បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារនៅក្នុងសាលក្រមព្រហ្មទណ្ឌចំនួន០២ ដោយឡែកពីគ្នា ហើយសាលក្រមព្រហ្មទណ្ឌ ទាំង០២នេះសុទ្ធតែបានចូលជាស្ថាពរអស់ហើយ ហើយទណ្ឌិតឈ្មោះ [redacted] រ៉ា ក៏បានអនុវត្តទោសនៅក្នុងពន្ធនាគារខេត្តកោះកុង បានចំនួន ០២(ពីរ)ឆ្នាំ ០៨(ប្រាំបី)ខែ ០៧ (ប្រាំពីរ)ថ្ងៃ រួចហើយដែរ ។ ម្យ៉ាងទៀតក្នុងរយៈពេលអនុវត្តទោសនៅក្នុងពន្ធនាគារ ទណ្ឌិតរូបនេះបានដឹងពីកំហុស បានគោរព-អនុវត្តយ៉ាងម៉ឺងម៉ាត់វិន័យ បទបញ្ជាផ្ទៃក្នុងនៅក្នុងពន្ធនាគារនឹងយកចិត្តទុកដាក់ក្នុងសកម្មភាពការងារពលកម្ម និងរៀនវិជ្ជាជីវៈ ប្រកបដោយស្មារតី ភ្ញាក់រលឹក ដើម្បីជាគំរូល្អ ដល់ទណ្ឌិតដទៃទៀត នឹងបានតាំងចិត្តកែប្រែខ្លួនដើម្បីកសាងខ្លួនជាពលរដ្ឋល្អ ជាប្រយោជន៍ដល់សង្គមជាតិ ក្រោយពេលអនុវត្តទោសចប់ ។ ហេតុដូច្នេះតុលាការ អាចប្រកាសឲ្យអនុវត្តទោសស្រុបបញ្ចូលគ្នាបាន ។

-តាមខ្លឹមសារនៃមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសឲ្យអនុវត្តទោសស្រុបបញ្ចូលគ្នាទាំងមូលក៏បានដែរ ។ ចំពោះសំណូមពររបស់មេធាវីការពារឲ្យទណ្ឌិតឈ្មោះ [redacted] រ៉ា និងទណ្ឌិតឈ្មោះ [redacted] រ៉ា ស្នើសុំឲ្យតុលាការស្រុបទោសបញ្ចូលគ្នា តុលាការអាចពិចារណា សម្រេចអំពីការស្រុបទោសបញ្ចូលគ្នាបាន ។

**<u>ហេតុដូច្នេះសាលាដំបូងខេត្តកោះកុង</u>**

**<u>វិនិច្ឆ័យសេចក្តី</u>**

**១- <u>ស្រុបទោសដែលមាននៅក្នុងសាលក្រមព្រហ្មទណ្ឌៈ</u>**

**ក-** លេខៈ **១០១-ក-** ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០៣(បី)ឆ្នាំ *ពីបទៈ* ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ០២ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីអំឡុងខែកក្កដា ឆ្នាំ២០១៧ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**ខ-** លេខៈ **១០២-ក-** ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកោះកុង បានសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ០៤(បួន)ឆ្នាំ តែទោសនេះត្រូវអនុវត្តដាក់ក្នុងពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ ទោសសល់ពីនេះត្រូវព្យួរទាំងអស់ *ពីបទៈ* ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ០២ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

- **ឲ្យទណ្ឌិតឈ្មោះ [redacted] រ៉ា** ភេទស្រី អាយុ ៤៧ឆ្នាំ ជនជាតិខ្មែរ អនុវត្តទោសដាក់ពន្ធនាគារ សរុបចំនួន០៤(បួន)ឆ្នាំតាមសាលក្រមព្រហ្មទណ្ឌទាំង២ខាងលើ នឹងតាមមាត្រា១៣៨ នៃក្រមព្រហ្មទណ្ឌ



Scanned with CamScanner

ក្រមនេះជំនុំជម្រះនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២០ ចំពោះមុខទណ្ឌិតឈ្មោះ [redacted]រ៉ា បើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| | |
|---|---|
| ក្រឡាបញ្ជីសវនាការ | ចៅក្រមជំនុំជម្រះ |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃព្រហស្បតិ៍ ០៩កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៣

កោះកុង, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០

ក្រឡាបញ្ជីសវនាការ

[redacted]

<u>បានឃើញ</u>

កោះកុង, ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០

ចៅក្រមជំនុំជម្រះ

[redacted]